**ប្រការ ២ :** ត្រូវទុកជានិរាករណ៍ សេចក្តីសំរេចលេខ ៨៦ សសរ ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាល ។

**ប្រការ ៣ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ និង បណ្តាស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| នាយករដ្ឋមន្ត្រីទី១ | នាយករដ្ឋមន្ត្រីទី២ |
|---|---|
| ព្រះហស្តលេខានិងត្រា | ហត្ថលេខានិងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

***

# ៣- សារាចរ

## សារាចរលេខ ០៧ សសរ

## ស្តីពីការខារសន្សំសំចៃ

ក្នុងកាលៈទេសៈដែលប្រទេសជាតិកំពុងត្រូវស្តារ និង កសាងឡើងវិញលើគ្រប់វិស័យ ការលំបាកធំ ៗ ដែលត្រូវដោះស្រាយចេះតែកើតមានឡើងជាបន្តបន្ទាប់ ជាអាទិសកម្មភាពបំផ្លិចបំផ្លាញ របស់ពួកឧទ្ទាមខ្មែរក្រហម និងគ្រោះធម្មជាតិ ។ ជាក់ស្តែងឆ្នាំនេះជាងឆ្នាំណាៗ ទាំងអស់ គ្រោះមហន្តរាយ នៃទឹកជំនន់ និងការរាំងស្ងួតបានកើតឡើងជួនៗបណ្តាល អោយមានការខូចខាតយ៉ាងធ្ងន់ធ្ងរដល់ប្រព័ន្ធគមនាគមន៍ លំនៅដ្ឋាន ទ្រព្យសម្បត្តិផលដំណាំផ្សេងៗ ព្រមទាំងមធ្យោបាយ ផលិតកម្មរបស់ប្រជាកសិករ ដែលរាជរដ្ឋាភិបាល ចាំបាច់ត្រូវប្រមូលអស់ លទ្ធភាពនូវថវិកាជាតិ និងប្រភពទុនផ្សេងៗទៀត ដែលមានដើម្បីធ្វើការស្តារ និងជួសជុលការខូចខាតទាំងនោះអោយដំណើរការជាប្រក្រតីឡើងវិញ និងជួយឧបត្ថម្ភប្រជារាស្ត្ររងគ្រោះអោយឆ្លងផុតពីគ្រោះទុរ្ភិក្ស ។

ទន្ទឹមនឹងថវិកាជាតិកំពុងមានកង្វះខាត រាជរដ្ឋាភិបាល បានពិនិត្យឃើញថា ការប្រើប្រាស់ និងការចាយវាយរបស់ក្រសួង ស្ថាប័ន ខេត្ត ក្រុង ភាគច្រើននៅមានភាពខ្ជះខ្ជាយ ខ្វះការសន្សំសំចៃ ដែលនៅមិនទាន់បានកែលំអនៅឡើយ ។

បាតុភាពខ្ជះខ្ជាយសន្សំសំចៃ តែងតែកើតមានឡើង ដោយសារមន្ត្រីជាថ្នាក់ដឹកនាំ ខ្វះស្មារតីទទួលខុសត្រូវខ្វះសមត្ថភាពក្នុងការគ្រប់គ្រងត្រួតពិនិត្យ ដែលបណ្តាលអោយមានភាពខ្ជះខ្ជាយលើពេលវេលាក្របខ័ណ្ឌកំលាំងពលកម្មថវិកាជាតិ និង ទ្រព្យសម្បត្តិរដ្ឋ ។

ដើម្បីពុះពារជំនះ នូវផលវិបាកទាំងនេះ និងដើម្បីជួយទ្រទ្រង់សន្សំថវិកាជាតិ និងទ្រព្យសម្បត្តិរដ្ឋ រាជរដ្ឋាភិបាល សូមលើកវិធានការមួយចំនួនសំរាប់អោយគ្រប់ក្រសួង ស្ថាប័ន ខេត្ត ក្រុង អនុវត្តការត្បិតត្បៀតសន្សំសំចៃដូចខាងក្រោម :

១- គ្រប់ក្រសួង ស្ថាប័ន ខេត្ត ក្រុង ត្រូវចលនា និង ណែនាំដល់អង្គភាព មន្ត្រីរាជការ គ្រប់ថ្នាក់នៅតាមផ្នែកសំខាន់ៗ ក្រោមឱវាទអោយមានទស្សនៈ និងសកម្មភាពចេះគិតគូរសន្សំសំចៃគ្រប់ពេលវេលា ។ ត្រូវពង្រឹង និងបង្កើនទំលាប់ សន្សំសំចៃ ក្នុងការប្រើប្រាស់ និងការចំណាយលើគ្រប់ផ្នែក ដោយចៀសវាងការរត់ប្រណាំងខាងភាពហ៊ឺហាខ្ជះខ្ជាយជាអាទិ :

ក- ការរៀបចំពិធីផ្សេងៗ : ក្នុងការរៀបចំពិធីបុណ្យជាតិ បុណ្យអន្តរជាតិ សន្និបាតបូកសរុបលទ្ធផលស្នាដៃការងារប្រជុំដោះស្រាយបញ្ហាទទួលប្រតិភូ ឬ ភ្ញៀវជាតិ ។ល។ បើអាចជៀសវាងការជប់លៀងបានត្រូវតែជៀស ។ ការចំណាយសំរាប់រៀបចំតុបតែងលំអ ចំណាយទិញសំភារៈប្រើប្រាស់ទទួលភ្ញៀវដូចជា ភេសជ្ជៈ បារី ជាដើម ។ល។ ត្រូវជ្រើសរើសទិញយកផលិតផលដែលផលិតបានក្នុងប្រទេស មានតម្លៃសមស្រប ។

ខ- ការប្រើប្រាស់ថាមពលអគ្គិសនី ទឹក : នៅតាមអាគារសាធារណៈ ពិសេសនៅតាមកន្លែងធ្វើការ អំពូលភ្លើងសំរាប់បំភ្លឺ ទឹក ក៏ដូចជាម៉ាស៊ីនត្រជាក់នៅតាម បន្ទប់នីមួយ ៗ ពេលចេញពីធ្វើការចាំបាច់ត្រូវបិទអោយអស់ លើកលែងតែភ្លើងអគ្គិសនីសំរាប់បំភ្លឺរួមនៅក្នុងទីតាំងនីមួយ ៗ ។

គ- ការប្រើប្រាស់ទូរស័ព្ទ : ទូរស័ព្ទនៅនឹងកន្លែង ក៏ដូចជាទូរស័ព្ទចល័តគ្រប់ប្រភេទ ដែលប្រើប្រាស់ទាក់ទងបានទាំងក្នុង និងក្រៅប្រទេស ត្រូវកាត់បន្ថយការប្រើប្រាស់អោយនៅកំរិតតិចជាអតិបរមា គឺនិយាយឆ្លើយឆ្លងតែការងារណាដែលចាំបាច់បំផុតខានមិនបាន ។ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវចេញគោលការណ៍ថ្មី ស្តីពីការប្រើប្រាស់ទូរស័ព្ទអោយបានសមស្រប ។

ឃ- ការប្រើប្រាស់រថយន្ត និង ប្រេងឥន្ធនៈ : រថយន្តគ្រប់ប្រភេទ ដែលជាអចលនៈទ្រព្យរបស់ ស្ថាប័ន-ក្រសួង និង ខេត្ត- ក្រុង ត្រូវកំណត់គោលការណ៍ប្រើប្រាស់បំរើការងារអោយបានត្រឹមត្រូវ និងសមហេតុផល ជៀសវាងការឆ្លៀត ឱកាសយកទៅបំរើការងារ ដើម្បីជាផលប្រយោជន៍ផ្ទាល់ខ្លួន ឬ ប្រើប្រាស់តាមរបៀបសំបូរបែប ។

ង- ការប្រើប្រាស់សំភារៈការិយាល័យ : សំភារៈការិយាល័យដូចជា ម៉ាស៊ីនកុំព្យូទ័រ ម៉ាស៊ីនអង្គុលីលេខ ម៉ាស៊ីន ថតចម្លង ។ ល ។ ត្រូវថែរក្សាការពារអោយបានល្អ ប្រើអោយបានចំទិស និងក្នុងលក្ខណៈសន្សំសំចៃខ្ពស់ ។

ច ប្រើប្រាស់គ្រឿងអាវុធ គ្រាប់រំសេវ : គ្រឿងអាវុធ និងគ្រាប់រំសេវគ្រប់ប្រភេទ សុទ្ធតែជាប្រភេទទំនិញ មានតំលៃ ដែលនាំចូលពីបរទេស ហើយត្រូវទូទាត់ដោយរូបិយប័ណ្ណខ្លាំង ។ ដូច្នេះទាមទារអោយក្រសួង ការពារជាតិអគ្គសេនាធិការនៃកងយោធពលខេមរភូមិន្ទ និងក្រសួងមហាផ្ទៃ ណែនាំយ៉ាងហ្មត់ចត់គ្រប់កងកំលាំង ប្រដាប់អាវុធអោយចេះ គ្រប់គ្រង និង ប្រើប្រាស់អោយបានសមស្រប បំរើអោយចំទិសដៅប្រយុទ្ធជាមួយ ខ្មាំង សត្រូវ ជៀសវាងការលួចយកទៅ លក់បន្តបំរើប្រយោជន៍ផ្ទាល់ខ្លួន ឬ យកទៅបាញ់លេងសប្បាយនៅឱកាសមានបុណ្យទាន ពេលមានព្យុះភ្លៀងធ្លាក់ខ្លាំង ឬ យកទៅបរបាញ់សត្វ និងគប់យកត្រី ។ ល ។

ឆ- ការរៀបចំគំរោងចំណាយសំរាប់បំរើកិច្ចការសំខាន់ ៗ : គំរោងចំណាយថវិកានីមួយ ៗ ត្រូវរៀបចំអោយបានច្បាស់លាស់ ពិតប្រាកដ និងមានលក្ខណៈសន្សំសំចៃអោយស្របទៅនឹងពេលវេលា និងទំហំនៃការងារ ដែលត្រូវធ្វើ ដោយមានការត្រួតពិនិត្យយ៉ាងហ្មត់ចត់ ពីអ្នកទទួលខុសត្រូវ ជៀសវាងការឆ្លៀតបំប៉ោងសំដៅធ្វើអោយគំរោងចំណាយស្នើសុំ មានភាពចំឡែងខុសពីភាពជាក់ស្តែង ។

២- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុត្រូវធ្វើការត្រួតពិនិត្យដោយមានសិទ្ធិកាត់បន្ថយ ឬ បដិសេធចោលលើសំណូមពរចំណាយណាដែលមិនចាំបាច់ ឬ យកទៅប្រើប្រាស់មិនចំទិសដៅ ។

៣- គណៈកម្មការបច្ចេកទេសអន្តរ... ដើម្បីកែទំរង់រដ្ឋបាលសាធារណៈ ត្រូវខិតខំកែលំអ រចនាសម្ព័ន្ធរដ្ឋបាលតាមផ្នែកនានា អោយបានឆាប់រហ័ស... ខ្សែសង្វាក់រដ្ឋបាលណាដែលមិនចាំបាច់ ព្រមទាំងរៀបចំបែងចែក និងប្រើប្រាស់ក្របខ័ណ្ឌបុគ្គលិកអោយអស់... បង្កើនប្រសិទ្ធភាព និងទិន្នផលការងារ ។

៤- ក្រសួង ស្ថាប័ន ខេត្ត ក្រុង នីមួយ ៗ ត្រូវរៀបចំចាត់ចែងអោយមាន កម្មវិធីអនុវត្តការងារ សន្សំសំចៃរៀងៗ ខ្លួន សំដៅប្រមែប្រមូលទុនដែលបានមកពីការសន្សំសំចៃនេះ យកទៅអភិវឌ្ឍន៍ភូមិឃុំណាដែលក្រក្សត់ជាងគេ ។

៥- ក្រសួងអប់រំយុវជន និង កីឡា ត្រូវរៀបចំបញ្ចូលទៅក្នុងកម្មវិធីសិក្សាផ្នែកបឋម សិក្សាអំពីការងារសន្សំសំចៃ ។

ក្រោយពេលទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័នរដ្ឋ និង គ្រប់ខេត្ត ក្រុង ចាត់ចែងផ្សព្វផ្សាយអោយបាន ទូលំទូលាយដល់មន្ត្រីរាជការទាំងអស់ក្រោមឱវាទ សំដៅអនុវត្តអោយមានប្រសិទ្ធភាពខ្ពស់តាមភារកិច្ចរៀង ៗ ខ្លួន ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឬទ្ធិ** | **ហ៊ុន សែន** |

***

*រាជធានីភ្នំពេញ , ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤*

## សារាចរលេខ ០៨ សរ

## ស្តីពីការជំរុញការងារបង្កបង្កើនផលរដូវប្រាំង ១៩៩៤ -១៩៩៥ និងរដូវវស្សា ១៩៩៥

ការងារបង្កបង្កើនផលរដូវវស្សា ១៩៩៤ កន្លងទៅនេះ បានជួបប្រទះនូវផលវិបាកជាច្រើនដែលបណ្តាលមកពីគ្រោះទឹកជំនន់ដែលបានបំផ្លាញអស់ផលដំណាំជាច្រើន ពិសេសដំណាំស្រូវដែលត្រូវទទួលការខូចខាតរាប់រយពាន់ ហ.ត ។ ទន្ទឹមនឹងគ្រោះទឹកជំនន់ដ៏សាហាវនេះ គ្រោះរាំងស្ងួតចុងរដូវវស្សាក៏បានរាតត្បាតលើតំបន់មួយចំនួនគួរអោយព្រួយបារម្ភ ។ បើរាជរដ្ឋាភិបាលពុំមានវិធានការក្នុងការអន្តរាគមន៍សង្គ្រោះទាន់ពេលវេលាទេនោះ ផ្ទៃដីដាំស្រូវមួយចំនួនធំត្រូវទទួលការខូចខាតយ៉ាងធំធេងដែលអាចនឹងជួបការលំបាកដោយសារការខ្វះខាតស្បៀងយ៉ាងធ្ងន់ធ្ងរសំរាប់ ឆ្នាំ ១៩៩៥ ដែលរាជរដ្ឋាភិបាលត្រូវប្រឈមមុខដោះស្រាយ ។ ចំពោះមុខសភាពការណ៍ដ៏សាហាវធ្ងន់ៗនេះ រាជរដ្ឋាភិបាលតាមរយៈក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ និង រដ្ឋអំណាចគ្រប់